ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត

បន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩៦

ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

សាលក្រមព្រហ្មទណ្ឌ

លេខ:៥៥(គ)/៤១៧

ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យនាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ[redacted] សូនេត ហៅ គង់ ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted]ខេត្តបាត់ដំបង អាសយដ្ឋានភូមិចារក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះ[redacted] លន (ស) ម្តាយឈ្មោះ[redacted] សំរិត (រ) ប្រពន្ធឈ្មោះ[redacted] ឡុំ មានកូន០៦នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុនគ្មាន ។

ដីកាបង្គាប់អោយឃុំខ្លួនលេខ៥១ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ។

**ដោយមានលោក[redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ**

ពីបទ សន្និធិអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិចារក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤៨៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១៨៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាដំណោះស្រាយលេខ១១៣៦ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ២៥៤ ពស.ព្រជ "ក"/២០ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៦ និង៣០នាទី មានឈ្មោះ[redacted] សំបូរ ភេទស្រី អាយុ៤៤ឆ្នាំ បានយកកាំភ្លើងអាកាស្វាយមួយដើម ផលិតនៅប្រទេសសូវៀត លេខ៤៩៥១០ បង់ចំនួន០២(ពីរ) គ្រាប់ចំនួន១៩(ដប់ប្រាំបួន)គ្រាប់ បានយកប្រគល់ឲ្យប៉ុស្តិ៍នគរបាលឃុំប្រាសាទ ដោយប្រាប់ថា មិនមែនជារបស់ខ្លួនឡើយ គាត់បានរកឃើញនៅផ្ទះគាត់ តាមគាត់ដឹងកាំភ្លើងនេះជារបស់បងគាត់ឈ្មោះ[redacted] សូនេត ហៅគង់ ភេទប្រុស អាយុ៥៣ឆ្នាំ បានយកទៅលាក់ទុកនៅផ្ទះគាត់ ដោយមិនបានប្រាប់ឡើយ ។ ក្រោយពីទទួលបានការរាយការណ៍ខាងលើសមត្ថកិច្ចបានចុះស្រាវជ្រាវ និងឃាត់ខ្លួនជនល្មើសឈ្មោះ[redacted] សូនេត ហៅ គង់ ភេទប្រុស អាយុ៥៣ឆ្នាំ បានតែម្តង ។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង និងបញ្ជូនជនល្មើសព្រមទាំងវត្ថុតាង មកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted] សូនេត ហៅ គង់ បានឆ្លើយថាៈកាលពីឆ្នាំ១៩៨១ ខ្លួនធ្លាប់ធ្វើទាហ៊ាននៅវីរៈ៤២ ឈរជើងនៅខេត្តឧត្តមានជ័យ ។ ក្រោយមកខ្លួនបានឈប់ធ្វើជាទាហ៊ាន ហើយយកកាំភ្លើងអាកាស្វាយចំនួន០១(មួយ)ដើម លេខ៤៩៥១០ ផលិតនៅប្រទេសសូវៀត និងគ្រាប់បែកចំនួន០១(មួយ)គ្រាប់ មកតាមខ្លួន ។ រហូតមកដល់ឆ្នាំ២០១៩ ខ្លួនបានយកកាំភ្លើង និងគ្រាប់បែកនោះមករក្សាទុកនៅផ្ទះខ្លួនស្ថិតនៅភូមិចារ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដោយមិនបានប្រាប់ប្រពន្ធនិងកូនៗ របស់ខ្លួនឲ្យដឹងឡើយ ។ នៅក្នុងឆ្នាំ២០១៩ ដដែលនោះខ្លួនបានទាស់ទែងជាមួយប្រពន្ធ ហើយបានចុះចោលផ្ទះមក រស់នៅជាមួយប្អូនស្រីរបស់ខ្លួនឈ្មោះលន សំបូរ អាយុ៤២ឆ្នាំ ស្ថិតនៅភូមិចារក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ហើយបានយកកាំភ្លើងមកទុកនៅផ្ទះប្អូនស្រីដោយមិនបានប្រាប់ប្អូនស្រីខ្លួនឲ្យដឹងឡើយ តែខ្លួនមិនបានយកគ្រាប់បែកមកជាមួយទេ គឺទុកនៅផ្ទះប្រពន្ធខ្លួនស្ថិតនៅភូមិចារ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ មូលហេតុដែលខ្លួនចេញពីទាហ៊ាន ហើយបានយកកាំភ្លើងនិងគ្រាប់បែកមកតាមខ្លួនដោយសារទុកការពារខ្លួន តែខ្លួនមិនធ្លាប់បានយកកាំភ្លើង និងគ្រាប់បែកនោះប្រព្រឹត្តបទល្មើសឡើយ ។ សំណូមពរ សុំអោយតុលាការបន្ធូរបន្ថយទោស ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ឡំ បានឆ្លើយថាៈ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ខ្លួនឡើងលើជង្រុក ដើម្បីរកពូថៅក៏ឃើញមានការ៉ុងមួយចងមាត់ជិតតែខ្លួនមិនដឹងថាជាអ្វីទេ

ហើយមិនបានបើកមើលដែរ ។ លុះដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែលបី ជិតភ្លឺ ខ្លួនបានឈ្លោះទាស់ទែងគ្នាជាមួយប្ដីឈ្មោះ[redacted] សូនេត ហៅ គង់ ហើយប្ដីខ្លួនបានវាយកំទេច ទ្រុងមាន់ ទ្រុងទា រុះរើជណ្ដើរផ្ទះ និងរើគ្រែផ្ទះ ។ បន្ទាប់ពីឈ្លោះប្រកែកគ្នាហើយប្ដីខ្លួនឈ្មោះ[redacted] សូនេត ហៅគង់ បានជិះម៉ូតូចេញក្រៅបាត់ ។ ពេលភ្លឺឡើង(ថ្ងៃខែឆ្នាំដដែល) ខ្លួនបានឡើងមើលលើជង្រុកម្ដងទៀត ក៏បាត់ការ៉ុងមិនឃើញ ហើយឃើញតែបង់កាំភ្លើងនៅទីនោះទេ ។ បន្ទាប់មកខ្លួនបានទៅជម្រាបមេភូមិចារក្រោម ថា ខ្លួនឃើញការ៉ុងចងមាត់ជិតសង្ស័យជាកាំភ្លើងរបស់ប្ដីខ្លួនឥឡូវបានបាត់ហើយ នៅសល់តែបង់កាំភ្លើង ។ ក្រោយមកស្រាប់តែមានសមត្ថកិច្ចមកដល់ផ្ទះខ្លួនហើយខ្លួនក៏ឲ្យបង់កាំភ្លើងនោះទៅសមត្ថកិច្ចតែម្ដង ។

សាក្សីឈ្មោះ[redacted] សំបូរ បានឆ្លើយថាៈ កាលពីអំឡុង ខែមករា ឆ្នាំ២០២០ បងប្រុសខ្លួនឈ្មោះ[redacted] សូនេត ហៅគង់ បានមកស្នាក់នៅផ្ទះរបស់ខ្លួនរហូតដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ស្រាប់តែឃើញឈ្មោះ[redacted] តុលា បានជិះម៉ូតូមកផ្ទះខ្លួនប្រាប់ថាបង[redacted] សូនេត ហៅគង់ ឲ្យមកយកកាំភ្លើងជូនសមត្ថកិច្ច ដោយគាត់ប្រាប់ថាកាំភ្លើងនោះលាក់ទុកក្រោមខ្នើយរបស់បងប្រុសឈ្មោះ[redacted] សូនេត ហៅគង់ គឺនៅក្នុងការ៉ុងពណ៌សចងមាត់ជិត ។ បន្ទាប់មកខ្លួនក៏បានរកឃើញការ៉ុងនោះ ហើយជិះម៉ូតូទៅជាមួយឈ្មោះ [redacted] តុលា យកទៅឲ្យសមត្ថកិច្ច ។ ខ្លួនមិនដឹងថាកាំភ្លើងនោះបងប្រុសខ្លួនឈ្មោះឃិប សូនេត ហៅគង់ បានយកមកទុកនៅផ្ទះខ្លួនតាំងពីពេលណានោះឡើយ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] តុលា បានឆ្លើយថាៈកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ ២០២០ បងធម៌ខ្លួនឈ្មោះ [redacted] សូនេត ហៅ គង់ បានទូរសព្ទមកប្រាប់ខ្លួនថាឲ្យជិះម៉ូតូទៅឧបប្អូនស្រីឈ្មោះ[redacted]សំបូរ និងសួររកកាំភ្លើងតែឈ្មោះ[redacted] សំបូរ មិនដឹងឡើយ ។ ពេលនោះនាំគ្នាដើររកក៏ឃើញកាំភ្លើង ហើយខ្លួននិងឈ្មោះ[redacted] សំបូរ យកកាំភ្លើងនោះមកជូនសមត្ថកិច្ចតែម្ដង ។ កន្លងមកខ្លួនមិនដឹងថា ឈ្មោះ[redacted]សូនេត ហៅ គង់ មានលាក់អាវុធឡើយ ។

តុលាការអានរបាយការណ៍០០៩ ការិ.ព្រ.ទ.ស្រ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ របស់ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ។

តុលាការអានកំណត់ហេតុទទួលវត្ថុចាប់យកចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

តំណាងអយ្យការសន្និដ្ឋានប្ដឹងសុំថាៈ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សី ក្រោយពីបានស្ដាប់របាយការណ៍របស់មន្ត្រីនគបាលយុត្តិធម៌ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ពិតជាកើតមាននូវអំពើសន្និធិអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ[redacted] សូនេត ហៅ គង់។ ដូច្នេះស្នើរសុំឲ្យតុលាការផ្ដន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។

មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សី និងក្រោយពីបានស្ដាប់របាយការណ៍របស់មន្ត្រីនគបាលយុត្តិធម៌ និងក្រោយពីបានស្ដាប់សន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថាកូនក្ដីខ្លួនបានសារភាពនៅទង្វើដែល

ខ្លួនបានប្រព្រឹត្តម្យ៉ាងទៀតកូនក្តីខ្លួនក៏មិនបានយកអាវុធនោះដើម្បីទៅប្រព្រឹត្តបទល្មើសផ្សេងទៀតឡើយ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្តល់ស្ថានសម្រាលដល់កូនក្តីរបស់ខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

- ក្រោយពីបានស្តាប់សន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

- ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

១.កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៦ និង៣០នាទី មានឈ្មោះ [redacted] សំបូរ បានយកកាំភ្លើងអាកាស្វាយមួយដើម ផលិតនៅប្រទេសសូវៀត លេខ៤៩៥១០ បង់ចំនួន០២(ពីរ) គ្រាប់ចំនួន១៩(ដប់ប្រាំបួន)គ្រាប់ បានយកប្រគល់ឲ្យប៉ុស្តិ៍នគរបាលឃុំប្រាសាទ ដោយប្រាប់ថា មិនមែនជារបស់ខ្លួនឡើយ តាមគាត់ដឹងកាំភ្លើងនេះជារបស់គាត់ឈ្មោះ [redacted] សូនេត ហៅគង់ ភេទប្រុស អាយុ៥៣ឆ្នាំ បានយកទៅលាក់ទុកនៅផ្ទះគាត់ ។ ក្រោយពីទទួលបានការរាយការណ៍ខាងលើសមត្ថកិច្ចបានចុះស្រាវជ្រាវ និងឃាត់ខ្លួនជនល្មើសឈ្មោះ [redacted] សូនេត ហៅ គង់ ភេទប្រុស អាយុ៥៣ឆ្នាំ បានតែម្តង ។

២.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សូនេត ហៅ គង់ បានឆ្លើយថាៈកាលពីឆ្នាំ១៩៨១ ខ្លួនធ្លាប់ធ្វើទាហ៊ាននៅវរៈ៤២ ឈរជើងនៅខេត្តឧត្តមានជ័យ ។ ក្រោយមកខ្លួនបានឈប់ធ្វើជាទាហ៊ាន ហើយយកកាំភ្លើងអាកាស្វាយចំនួន០១(មួយ)ដើម លេខ៤៩៥១០ ផលិតនៅប្រទេសសូវៀត និងគ្រាប់បែកចំនួន០១(មួយ)គ្រាប់ មកតាមខ្លួន និងយកមករក្សាទុកនៅផ្ទះខ្លួនស្ថិតនៅភូមិចារ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដោយមិនប្រាប់ប្រពន្ធនិងកូនៗ របស់ខ្លួនឲ្យដឹងឡើយ ។ នៅក្នុងឆ្នាំ២០១៩ ដដែលនោះខ្លួនបានទាស់ទែងជាមួយប្រពន្ធ ហើយបានចុះចោលផ្ទះមក រស់នៅជាមួយប្អូនស្រីរបស់ខ្លួនឈ្មោះ [redacted] សំបូរ នៅភូមិចារក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ហើយបានយកកាំភ្លើងមកទុកនៅផ្ទះប្អូនស្រីដោយមិនបានប្រាប់ប្អូនស្រីខ្លួនឲ្យដឹងឡើយ តែខ្លួនមិនបានយកគ្រាប់បែកមកជាមួយទេ គឺទុកនៅផ្ទះប្រពន្ធខ្លួនស្ថិតនៅភូមិចារ ឃុំប្រាសាទ ស្រុក ព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ មូលហេតុដែលខ្លួនចេញពីទាហ៊ាន ហើយបានយកកាំភ្លើងនិងគ្រាប់បែកមកតាមខ្លួនដោយសារទុកការពារខ្លួន តែខ្លួនមិនធ្លាប់បានយកកាំភ្លើង និងគ្រាប់បែកនោះប្រព្រឹត្តបទល្មើសឡើយ ។

៣.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ឡាំ បានឆ្លើយថាៈ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ខ្លួនឡើងលើជង្រុក ដើម្បីរកពូថៅក៏ឃើញមានការុងមួយចងមាត់ជិតតែខ្លួនមិនដឹងថាជាអ្វីទេ ហើយមិនបានបើកមើលដែរ ។ លុះដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែលបីជិតភ្លឺ ខ្លួនបានឈ្លោះទាស់ទែងគ្នាជាមួយប្តីឈ្មោះ [redacted] សូនេត ហៅ គង់ ហើយប្តីខ្លួនបានវាយកំទេចទ្រុងមាន់ ទ្រុងទា រុះរើជណ្តើរផ្ទះ និងរើគ្រែផ្ទះ ។ បន្ទាប់ពីឈ្លោះប្រកែកគ្នាហើយប្តីខ្លួនឈ្មោះ [redacted] សូ

នេត ហៅគង់ បានជិះម៉ូតូចេញក្រៅបាត់ ។ ពេលភ្លឺឡើង(ថ្ងៃខែឆ្នាំដដែល) ខ្លួនបានឡើងមើលលើជង្រុកម្តងទៀត ក៏បាត់ការ៉ុងមិនឃើញ ហើយឃើញតែបង់កាំភ្លើងនៅទីនោះទេ ។ បន្ទាប់មកខ្លួនបានទៅជម្រាបមេភូមិចាវក្រោម ថា ខ្លួនឃើញការ៉ុងចងមាត់ជិតសង្ស័យជាកាំភ្លើងរបស់ប្តីខ្លួនឥឡូវបានបាត់ហើយ នៅសល់តែបង់កាំភ្លើង ។ ក្រោយមកស្រាប់តែមានសមត្ថកិច្ចមកដល់ផ្ទះខ្លួនហើយខ្លួនក៏ឲ្យបង់កាំភ្លើងនោះទៅសមត្ថកិច្ចតែម្តង ។

៤.តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] សំបូរ បានឆ្លើយថាៈ កាលពីអំឡុង ខែមករា ឆ្នាំ២០២០ បងប្រុសខ្លួនឈ្មោះ[redacted] សូនេត ហៅគង់ បានមកស្នាក់នៅផ្ទះរបស់ខ្លួនរហូតដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ស្រាប់តែឃើញឈ្មោះ[redacted] តុលា បានជិះម៉ូតូមកផ្ទះខ្លួនប្រាប់ថាបង[redacted] សូនេត ហៅគង់ ឲ្យមកយកកាំភ្លើងជូនសមត្ថកិច្ច ដោយគាត់ប្រាប់ថាកាំភ្លើងនោះលាក់ទុកក្រោមខ្មើយរបស់បងប្រុសឈ្មោះ[redacted] សូនេត ហៅគង់ គឺនៅក្នុងការ៉ុងពណ៌សចងមាត់ជិត ។ បន្ទាប់មកខ្លួនក៏បានរកឃើញការ៉ុននោះ ហើយជិះម៉ូតូទៅជាមួយឈ្មោះ[redacted] តុលា យកទៅឲ្យសមត្ថកិច្ច ។ ខ្លួនមិនដឹងថាកាំភ្លើងនោះបងប្រុសខ្លួនឈ្មោះ[redacted] សូនេត ហៅគង់ បានយកមកទុកនៅផ្ទះខ្លួនតាំងពីពេលណានោះឡើយ ។

៥.តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] តុលា បានឆ្លើយថាៈកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ បងធម៌ខ្លួនឈ្មោះ [redacted] សូនេត ហៅ គង់ បានទូរសព្ទមកប្រាប់ខ្លួនថាឲ្យជិះម៉ូតូទៅឧបប្អូនស្រីឈ្មោះ[redacted] សំបូរ និងសួររកកាំភ្លើងតែឈ្មោះ[redacted] សំបូរ មិនដឹងឡើយ ។ ពេលនោះនាំគ្នាដើររកក៏ឃើញកាំភ្លើង ហើយខ្លួននិងឈ្មោះ[redacted] សំបូរ យកកាំភ្លើងនោះមកជូនសមត្ថកិច្ចតែម្តង ។ កន្លងមកខ្លួនមិនដឹងថា ឈ្មោះ[redacted] សូនេត ហៅ គង់ មានលាក់អាវុធឡើយ ។

៦.តាមការរៀបរាប់ខាងលើនេះបង្ហាញឲ្យឃើញថាសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted] សូនេត មិនមានជាតុផ្សំគ្រប់គ្រាន់ពីបទ **សន្និធិអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត** ប៉ុន្តែជនជាប់ចោទបានសារភាពថា ខ្លួនកាន់កាប់អាវុធមានកាំភ្លើងអាកានិងបង់ចំនួនពីរ គ្រាប់ចំនួន១៩គ្រាប់ និងបានយកអាវុធផ្ទះរបស់ខ្លួនទៅទុកនៅផ្ទះប្អូនស្រីដោយច្រកការ៉ុង ។ ដូច្នេះគប្បីតុលាការប្តូបទចោទទៅជាបទ **កាន់កាប់ និងដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចភូមិចាវក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ ។

៧.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] សូនេត ហៅ គង់ ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរពីបទ **កាន់កាប់ និងដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាតត** ប្រព្រឹត្តនៅចំណុចភូមិចាវក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ ។

៨.តាមកំណត់ហេតុទទួលវត្ថុចាប់យកចុះថ្ងៃទី២២ ខែមករា ឆ្នាំ រួមមានៈ

-កាំភ្លើងអាកាស្វាយចំនួន០១(មួយ)ដើម លេខ៤៩៥១០ ផលិតនៅប្រទេសសូវៀត មានបង់ចំនួន០២(ពីរ) និងគ្រាប់ចំនួន១៩(ដប់ប្រាំបួន)គ្រាប់ ។ តាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

៩. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ស្នើសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។

## ហេតុដូច្នេះទើបសម្រេច

១.ផ្តន្ទាទោសលើឈ្មោះ[redacted] សូនេត ហៅ គង់ ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ កំណត់ដាក់ពន្ធនាគាររយៈពេល**០២(ពីរ)ឆ្នាំ** ពីបទ កាន់កាប់ និងដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិចារក្រោម ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ ។

២.រឹបអូសវត្ថុតាងតាមកំណត់ហេតុទទួលវត្ថុចាប់យកចុះថ្ងៃទី២២ ខែមករា ឆ្នាំរួមមាន:

-កាំភ្លើងអាកាស្វាយចំនួន០១(មួយ)ដើម លេខ៤៩៥១០ ផលិតនៅប្រទេសសូវៀត មានបង់ចំនួន០២(ពីរ) និងគ្រាប់ចំនួន១៩(ដប់ប្រាំបួន)គ្រាប់ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០.០៥.២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បន្ទាយមានជ័យ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]